ការសំភាសន៍របស់ គង់ ធូ

កៈ អ្នកដែរសំភាសន៍គេ ជាង ស៊ីអ៊ារ   ខៈ អ្នកដែរអោយគេសំភាសន៍ គង់ ធូ

កៈ
ចឹងជាដំបូងខ្ញុំអរគុណអ៊ុំដែរបានអោយខ្ញុំសំភាសន៍ដែរទាក់ទងពីប្រវត្តិរបស់អ៊ុំហាសហើយការសំភាសន៍នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅសហរដ្ឋអាមេរិចហាសដែរមានឈ្មោះថាBYU
ហើយដោយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗបានស្គាល់ពីប្រវត្តិដូនតាហាសអ៊ុំដល់ពេលដែរខ្ញុំសំភាសន៍ហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ហាសអ៊ុំ ចឹងខ្ញុំសំភាសន៍អ៊ុំនៅភូមិ5 ឃុំអំពិល សង្កាត់ចំការមន ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញហាសអ៊ុំចឹងសំរាប់អ៊ុំខ្ញុំមានឈ្មោះជាង ស៊ីអ៊ារ ខ្ញុំសំភាសន៍នៅថ្ងៃទី17 ខែមករា
ឆ្នាំ2017ហាសអ៊ុំហើយនៅពេលដែរខ្ញុំសំភាសន៍អ៊ុំហើយខ្ញុំនឹងដាក់ការសំភាសន៍របស់អ៊ុំទៅក្នុងវេបសាយរបស់សាលាចុះអ៊ុំយលព្រមដើម្បីអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់អ៊ុំដែរទេអ៊ុំ?

ខៈ មានអីទេ

កៈ បានមែនទេអ៊ុំចឹងខ្ញុំអាចសុំដាក់នៅកន្លែងនេះដើម្បីនៅជិតសំលេងអ៊ុំដែរចឹងហាសអ៊ុំបាទចឹងសំរាប់អ៊ីឈ្មោះពេញរបស់អ៊ុំមានឈ្មោះអីគេដែរអ៊ុំ?

ខៈ ខ្ញុំឈ្មោះគង់ ធូ ពិតតែម្តងអត់មានកែអីទេ ឈ្មោះគង់ ធូ

កៈ ឈ្មោះគង់ធូ ចុះមានឈ្មោះហៅក្រៅអត់អ៊ុំ?

ខៈ អត់មានទេ

កៈ ចុះកាលនៅពីតូចមានគេធ្លាប់ហៅឈ្មោះអ៊ុំអីផ្សេងទៀតទេអ៊ុំ?

ខៈ អត់មានតែម្តងមានតែមួយនឹងអែង

កៈ អូតែមួយនឹងទេណ?

ខៈ អ៊ុំមិនដែរប្តូរត្រកូលអីទេ

កៈ ចុះអ៊ុំសព្វថ្ងៃនឹងអ៊ុំអាយុប៉ុន្មានដែរអ៊ុំ?

ខៈ ខ្ញុំអាយុ50ឆ្នាំគត់

កៈ អ៊ុំអាយុ50ឆ្នាំគត់ ចុះអ៊ុំបានកើតនៅថ្ងៃណា ខែណា ឆ្នាំណាអ៊ុំមានចងចាំទេអ៊ុំ?

ខៈ ខ្ញុំថ្ងៃដូចជាអត់ចាំបើឆ្នាំចងចាំ

កៈ ចឹងខែក៏អត់ចាំដែរណាអ៊ុំ?

ខៈ ខែអត់មានបានចាំទេ

កៈ ចុះបើឆ្នាំឆ្នាំណាដែរអ៊ុំ?

ខៈ នៅឆ្នាំ1969

កៈ នៅឆ្នាំ1969ចុះអ៊ុំមានចងចាំឆ្នាំច័ន្ទគតិអីទេអ៊ុំដូច ឆ្នាំជូត ឆ្លូវ ខាល ថោះអីហោសអ៊ុំ?

ខៈ ខ្ញុំឆ្នាំរកា

កៈ ឆ្នាំរកាហោសអ៊ុំ ចុះទីកន្លែងកំណើតរបស់អ៊ុំអ៊ុំកើតនៅណាវិញហោសអ៊ុំ?

ខៈ ស្រុកកំណើតខ្ញុំកើតនៅភូមិស្រុករការ

កៈ ចុះឃុំអីគេដែរអ៊ុំ?

ខៈ ឃុំឈើទាល

កៈ ចុះស្រុក នឹងខេត្តអីគេដែរអ៊ុំ?

ខៈ ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង

កៈ អូខេត្តស្វាយរៀងហោសអ៊ុំ ចុះអ៊ុំមានបងប្អូនចំនួនប៉ុន្មាននាក់ដែរហោសអ៊ុំ?

ខៈ ខ្ញុំមានបងប្អូន6នាក់

កៈ ចុះអ៊ុំជាកូនទីប៉ុន្មានដែរអ៊ុំ?

ខៈ ខ្ញុំជាកូនបងគេ

កៈ អ៊ុំបងគេចុះមានស្រីប៉ុន្មាននាក់ ហើយប្រុសប៉ុន្មាននាក់ដែរអ៊ុំ?

ខ៖ អត់មានស្រីទេប្រុសទាំងអស់

ក៖ ចុះបងប្អូនរបស់អ៊ុំមានឈ្មោះអីគេខ្លះអ៊ុំអាចរៀបរាប់បានទេអ៊ុំ?

ខ៖ ខ្ញុំអាចរៀបរាប់បានតាតែក្រែងលោកគ្រូអែងសើចអា3នាក់ណុង

ក៖ ឈ្មោះអីគេដែរអ៊ុំ?

ខ៖ ខ្ញុំឈ្មោះបងគេ គង់ធូ បន្ទាប់មកឈ្មោះគង់ម៉ាប់ ដែរបន្ទាប់ពីខ្ញុំហាស ទី3ឈ្មោះឡឹក ជាអានឹងម៉ែក្រោយ ដល់ពេលម៉ែខ្ញុំវិញអានឹងបានត្រកូលគង់វិញ

ក៖ ចឹងមានន័យថាអ៊ុំមានម៉ែ2នាក់ណអ៊ុំ?

ខ៖ នឹងហើយបន្ទាប់មកឈ្មោះគង់ អេ អានឹងស្រីដែរបានស្លាប់បាត់ទៅតែដល់ពេលពិបាកពេកបានដាក់វានៅលើចង្កេទៅវារស់ ដល់មកអាទី4ឈ្មោះគង់ អី ដល់ពេលមកទៀតឈ្មោះគង់ ជ្រែង

ក៖ អូឈ្មោះបងប្អូនរបស់អ៊ុំចំឡែក

ខ៖ ស្តាប់ទៅលោកគ្រូអែងសើចមើលត្រូវនៅ6នាក់នឹង

ក៖ មើល គង់អេ គង់អី គង់អែង គង់ជ្រែង ហើយនឹងអ៊ុំគង់ ធូ ហើយនឹងម្នាក់ទៀត?

ខ៖ ម្នាក់ទៀតមិញនឹងគង់អី

ក៖ ចុះអ៊ុំមានសាច់រឿងអីគេខ្លះដែរអ៊ុំគិតថាមានសាច់រឿងធ្លាប់បានធ្វើអីជាមួយពួកគាត់កាលពីអ៊ុំនៅក្មេងៗហាសអ៊ុំ?

ខ៖ ខ្ញុំដឹងសាច់រឿងកាលណុងខ្ញុំដឹងមែនកាលណុងឪពុកម្តាយរបស់ខ្ញុំនឹងគាត់ក្រព្រោះអីជីវប្រវត្តិខ្ញុំនឹងឪពុកម្តាយរបស់ខ្ញុំនឹងម្តាយរបស់ខ្ញុំបានចាប់បន្លែគេបន្តិចមកលក់នឹងហើយសំរាប់ឪពុកខ្ញុំនឹងខ្ញុំបងគាត់បានធ្វើកូនបង្គីអោយខ្ញុំតែប៉ុននេះទេបានរែកដីពីរនាក់គាត់សំរាប់ចាក់ភ្ជូមិហើយមិនរាក់ទេត្រពាំងនឹងហាសលោកគ្រូហើយបានរែកជាមួយគាត់រែកៗ

ក៖ អូអ៊ុំធ្វើបង្គីសំរាប់កើបដីចាក់ត្រពាំង?

ខ៖
នឹងហើយពុកខ្ញុំគេបាននៅមកភ្នំពេញនឹងហេសគេបាននៅគាត់មកភ្នំពេញពួកម៉ាក់គាត់នឹងថាទៅជាមួយអញ់ថាទៅទៅមែនពេលដែលមកគាត់រើសបានមាស1ដំលឹងដល់ចឹងគាត់បានបកទៅវិញដល់ពេលដែរគាត់បានបកទៅវិញគាត់ប្រាប់ថាកូនហាកូនអែងចូលរៀនវិញទៅកូនមិនបាច់រែកអីទៀតទេកូនហើយដល់ពេលដែរមកពីរៀនវិញកូនអែងដាំដើមឈើ

ក៖ ដាំដើមឈើធ្វើអីគេដែរអ៊ុំ?

ខ៖
ពេលដែរគាត់លក់មាសនឹងគាត់បានទិញខោអាវអោយខ្ញុំបាន1កំផ្លេហើយគាត់បានជួលគេរែកចាក់ទាល់តែពេញត្រពាំងនឹងហើយគាត់ចាប់ផ្តើមរកស៊ីជីកជ្រូកតែកង់មួយនឹងសំរាប់ជីកជ្រូកយកមកដូរយកអង្ករមកអោយកូនមិនអោយកូនពិបាកទេទោះជាគាត់ក្រមែនតែគាត់មិនអោយកូនពិបាកទេបាទគាត់ពុះពារគ្រប់ឧបសគ្គរបស់គាត់
ដូចខ្ញុំសព្វថ្ងៃមែនខ្ញុំក្រតែខ្ញុំមិនអោយកូនលំបាកទេអោយតែសប្បាយជាមួយគ្នានឹង

ក៖
ចុះអ៊ុំកាលពីក្មេងអ៊ុំចូលចិត្តលេងអីជាមួយនឹងបងប្អូនរបស់អ៊ុំដែរដូចជាលេងឡឹកបាយឡលេងបិទពួននឹងលេងអីចឹងហាសអ៊ុំ?

ខ៖ អានឹងខ្ញុំដូចជាអត់ត្រូវការទេ

ក៖
ចុះអ៊ុំលេងអីជាមួយពួកគាត់លក្ខណះថាចូលចិត្តលេងអីជាមួយនឹងពួកគាត់ហាសកាលពីនៅក្មេងហាសអ៊ុំ?

ខ៖ កាលពីក្មេងខ្ញុំចូលចិត្តជាគេគឺប្អូនរបស់ខ្ញុំគឺប្អូនទាំងអស់

ក៖ តែអ៊ុំចូលចិត្តលេងអីគេដែរអ៊ុំ?

ខ៖ ចូលចិត្តតែលេងបិទពួន
លក្ខណះថាបោះដំថ្មអោយគេទៅរើសអីចឹងហាសហើយបានរត់ទៅពួនបាត់ហើយបានស្រែកហៅ

កៈ អាគេលក្ខណៈថាលេងសាញ៉េនឹងហោសអ៊ុំ
អាគេគប់ទៅហើយគេហៅសាញ៉េនឹងហោសអ៊ុំ?

ខៈ
នឹងហើយហើយវារត់ទៅរើសហើយវាទៅរកនឹងពេលដែរខ្លាចប្អូនវាយំទៅក៏បានចេញមកបាទអានឹងខ្ញុំចេះលេងតែប៉ុណ្ណឹងអែង

កៈ ចឹងអត់មានអីដែរថាអ៊ុំចូលចិត្តលេងអីជាមួយប្អូនទៀតទេណាអ៊ុំ?

ខៈ
ប្អូនរបស់ខ្ញុំមិនសូវជាលេងអីច្រើនទេតែបើត្រូវជាចេញពីរៀនមកវិញមានតែពរទៅលេងហើយក៏នាំទៅមុជទឹកបានប្រលេញទៅ

កៈ ចុះអ៊ុំមានធ្លាប់បានទៅស្រែហើយទៅលេងទឹកអីមានទេ?

ខៈ អានឹងអត់ទេមិនដែរទៅទេ

កៈ ចឹងអត់ទេណាអ៊ុំ?

ខៈ
មិនដែរសោះម៉ងនឹងនឹងខ្ញុំនិយាយប្រាប់គ្រូចឹងបើថានាំប្អូនទៅលេងស្រែលេងទឹកលេងអីពីព្រោះមានឈ្លើង
ហើយម្យ៉ាងវិញទៀតប្អូនរបស់យើងវានៅទូចហើយចុះបើមានរណ្ដៅជ្រៅអីទៅយើហាចំណែកយើងនេះបើភ្លេចខ្លួនអីទៅយ៉ាងម៉េចទៅពីព្រោះនៅស្រុកស្រែខ្ញុំមានខូចច្រើនណាស់មានស្លាប់ច្រើនណាស់

កៈ ហេតុអីបានគេស្លាប់អ៊ុំ?

ខៈ
អារឿងលេងទឹកនៅស្រែនឹងលក្ខណៈថាអាបងនាំអាប្អូនទៅដល់ពេលដែរបងកំពុងតែលេងសប្បាយលេងលោតទឹកនោះដល់ពេលអាប្អូនឃើញក៏បានលោតតាមទៅអាប្អូនអត់ចេះហែលទឹកក៏បានស្លាប់បាត់ទៅ

កៈ ដូចលេងចាប់ក្ដាមចាប់ត្រីអី?

ខ៖ នឹងហើយៗដល់ពេលអាប្អូនវាឃើញវាចេះតែទៅតាមហើយ តែបើខ្ញុំអត់ទេអារឿងចឹងៗអីខ្ញុំសុខចិត្តថានាំប្អូនងូតទឹកនៅផ្ទះសព្វទឹកចឹងទៅងូតហើយនាំគ្នាស្លៀកពាក់ចឹងទៅ ហើយឪខ្ញុំបានទៅវៀតណាមនោះលោកគ្រូក៏គាត់ដឹកទៅហើយវៀតណាមគេបានស្គាល់គាត់គេបានអោយ100ដើមលក្ខណះថាអាខ្យល់នោះបាទខ្ញុំចេះដាំដូចថា100ដើមខ្ញុំដាំវាមិនអស់ទេបានពន្លក់អណ្ដៅវានឹងហើយបានដាក់អាចម៍គោយើងបើយើងមិនធ្វើចឹងទេវាមិនល្អអត់ងាយធំទេដល់ចឹងខ្ញុំដាំមួយថ្ងៃ40-50ដើម

ក៖ អូដាំបានច្រើនម្ល៉េសអ៊ុំ?

ខ៖ នឹងហើយវាស្រួលដាំដែរនឹងដល់ក្រោយមកដាំខ្នុរ នឹងដាំស្វាយចេះតែដាំៗទៅតែនេះមិនបានមកយើងទេបានតែយើងទៅនឹងហើយចឹងយើងចង់បេះៗទៅស្អីក៏បានដែរមានស្វាយ ដូងចឹងទៅ

ក៖ ចុះឥឡូវពួកគាត់នៅទីណាហើយប្អូនរបស់អ៊ុំគាត់រកស៊ីអីគេដែរអ៊ុំ?

ខ៖ ប្អូនៗខ្ញុំបើតាមនិយាយទៅមានតែមួយទេដែរខ្ពស់ជាងគេខាងរកស៊ីនៅស្រុកនឹង

ក៖ ចុះប្អូនទី2អ៊ុំគាត់បានធ្វើអីគេដែរអ៊ុំ?

ខ៖ មាន4នាក់ប្អូនរបស់ខ្ញុំអាទី2នៅស្រុក

ក៖ តែពួកគាត់ធ្វើអីគេធ្វើស្រែចំការទៅហោសអ៊ុំ?

ខ៖ ធ្វើស្រែចំការណុងហើយវាលក់នុំប៉ុង

ក៖ អូគាត់លក់នុំប៉ុងហោសអ៊ុំ?

ខ៖ នឹងហើយលក្ខណះថានុំប៉ុងរម៉កយើងចឹងដាក់សាច់គោអាំងដាក់អីជាមួយចឹងទៅ

ក៖ ចុះទី3គាត់ធ្វើអីគេដែរអ៊ុំ?

ខ៖ អាទី3នឹងវារត់ម៉ូតូឌុប

ក៖ រត់ម៉ូតូឌុប ចឹងគាត់រត់តែម៉ូតូឌុបទេហោសអ៊ុំ ចុះទី4វិញ?

ខ៖ បាទតែប្រពន្ធខូចពេកជេម៉ែពេក ហើយអាទី4គេបើកហាងធំហាស

កៈ អូគាត់បើកហាហាងហោសអ៊ុំ?

ខៈ
បើកហាងបើតាមនិយាយទៅកូនវា2នាក់នឹងដេកស៊ីមួយជីវិតមិនអស់ផងទើសតែអាមួយនឹង

កៈ តែគាត់បើកហាងនៅណាដែរអ៊ុំ នៅស្វាយរៀងនឹង?

ខៈ នៅស្រុកនឹងនៅជិតផ្ទះខ្ញុំនឹងហើយវានៅកែងផ្សារចឹង

កៈ អូចុះទី5គាត់ធ្វើអីគេដែរអ៊ុំ?

ខៈ អាទី5វានៅស្រុកដែរ

កៈ គាត់រកស៊ីអីគេដែរអ៊ុំ?

ខៈ អាណុងធ្វើតែស្រែទេ វាមានគោយន្តមួយមិនគិតអីទេ
តែកូនវារៀន3នាក់នឹងរៀនបានឌីផ្លូមទាំងអស់នឹងទាំង3នាក់នឹង

កៈ អូចុះទី6គាត់ធ្វើអីគេដែរអ៊ុំ?

ខៈ អាទី6អានឹងក៏គ្រាន់បើរបស់វាដែរនៅប្រសិទ្ធិ

កៈ អូនៅភ្នំប្រសិទ្ធិហោសអ៊ុំ?

ខៈ នឹងហើយវាប្រពន្ធនៅទីនោះឪក្មេកវាអោយបឹង
ហើយឪក្មេកវាបើកអោយលក់វាលក់បានជាង10ម៉ឺនពេលដែរបានជាង10ម៉ឺននោះវាយកទៅទិញអាឡានទេសចរណ៍ទៅកោះកុង
ពេលដែរទិញហើយជួលគេអោយរត់ធ្វើត្រកុងឡានឥឡូវវាធូរធារបស់វាធូរបានតែ2នាក់ទេបងប្អូនរបស់ខ្ញុំនឹងអានឹងបងប្អូន6នាក់របស់ខ្ញុំ

កៈ ប៉ុន្តែបងប្អូនរបស់អ៊ុំរស់នៅជិតគ្នាទាំងអស់រឺមួយក៏នៅឆ្ងាយពីគ្នា?

ខៈ បែកឆ្ងាយពីគ្នាតែអាមួយណុងនៅភ្នំប្រសិទ្ធិ

កៈ
បែកតែនៅភ្នំប្រសិទ្ធិនឹងមួយទេក្រៅពីនឹងបងប្អូនរបស់អ៊ុំពួកគាត់រស់នៅស្វាយរៀងទាំងអស់ណអ៊ុំ?

ខៈ ក្រៅពីនឹងនៅស្វាយរៀងទាំងអស់

កៈ ប៉ុន្តែអ៊ុំនៅទីនេះ?

ខៈ នឹងហើយខ្ញុំនៅទីនេះដល់ពេលដែរមានរវល់រឺមួយក៏ចូលឆ្នាំអីទៅជុំគ្នា

កៈ អូចឹងមានន័យថាទាល់តែមានរវល់អីបានបងប្អូនរបស់អ៊ុំទៅជុំគ្នាទាំងអស់?

ខៈ
នឹងហើយតែខ្ញុំគេមិនអោយធ្វើអីទេបងអង្គុយអោយស្រួលទាំងបងប្អូនរឺមួយក្មួយៗលើកអីអោយហូបចឹងគេមិនអោយធ្វើអីទេតិចលើកម្ហូបអាហារអោយហើយ
តែខ្ញុំបានផ្លាក់ខ្លួនឈឺ2ឆ្នាំនេះមកប្អូនៗរបស់គេអោយថវិការអោយខ្លះដែរនឹង

កៈ បាទអ៊ុំម្តាយរបស់អ៊ុំគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខៈ ម្តាយរបស់ខ្ញុំមានតែម្តាយក្រោយទេ

កៈ ចឹងអ៊ុំមានតែម្តាយក្រោយហោសអ៊ុំ?

ខៈ
បើម្តាយរបស់ខ្ញុំមុននឹងគាត់វៀតណាមសុទ្ធអាពតបានសំលាប់ចោលកាលពីជំនាន់អាពតមកហើយនៅតែម្តាយក្រោយទេ

កៈ ចុះម្តាយក្រោយមានឈ្មោះអីគេដែរអ៊ុំ?

ខៈ គាត់មានឈ្មោះអ៊ុក សឹម

កៈ ប៉ុន្តែគាត់នៅរស់សព្វថ្ងៃ?

ខៈ នៅរស់សព្វថ្ងៃនឹង

កៈ តែគាត់នៅស្វាយរៀងនឹងមែន?

ខៈ គាត់នៅស្រុកនឹងតែម្តាយក្រោយមែនតែម្តាយមុននឹងចិត្តអត់បានដូចគាត់ទេ

កៈ ម្តាយក្រោយចិត្តបាន?

ខៈ
មានស្អីកូនណាទៅចង់យកអីយកទៅកូនហូបចុះអោយតែហូបបានអត់មានអីណាដូចថា លោកគ្រូអែងចឹងចុះឧទាហរណ៍ហាសមានការខ្វះខាត់អីចឹងហាសម៉ែអើយ2ម៉ឺនទៅ3ម៉ឺនអី ចឹងយកទៅកូនមើលលើងទៅយកខ្លួនអែងទៅ

កៈ ចុះឪពយករបស់អ៊ុំគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខៈ គាត់មានឈ្មោះថាគង់ សឿ

កៈ អូគង់ សឿគាត់រស់នៅសព្វថ្ងៃរឺមួយក៏គាត់?

ខៈ គាត់រស់នៅសព្វថ្ងៃនឹងតែគាត់ចាស់ហើយ

កៈ ចឹងមានន័យថាទាំងម្តាយទាំងឪពុករបស់អ៊ុំពួកគាត់នៅរស់សព្វថ្ងៃនឹងទេ

ខៈ ពួកគាត់នៅរស់សព្វថ្ងៃនឹង

កៈ អូឡូយណាស់ចឹង

ខៈ គាត់នៅមើលតែចៅនឹង

កៈ ចុះឪពុករបស់អ៊ុំនឹងគាត់បានកើតនៅថ្ងៃខែ ឆ្នាំណាអ៊ុំមានបានដឹងអត់អ៊ុំ?

ខៈ អានឹងខ្ញុំអត់បានដឹងទេ

កៈ ប៉ុន្តែបានដឹងឆ្នាំអត់អ៊ុំ?

ខៈ ឆ្នាំនឹងគាត់អាយុ68ឆ្នាំ

កៈ គាត់អាយុ68ឆ្នាំ

ខៈ នឹងហើយគាត់ឆ្នាំនេះ68ឆ្នាំហើយ

កៈ ប៉ុន្តែអ៊ុំមានដឹងថាឆ្នាំខ្មែរគាត់ឆ្នាំអ៊ុំទេអ៊ុំលក្ខណៈថា ឆ្នាំជូត ឆ្លូវ ខាល ថោះអីហាស?

ខៈ អានឹងខ្ញុំអត់ដឹងទេ

កៈ អ៊ុំអត់ដឹងទេណា?

ខ៖ តែបើលោកគ្រូមានដឹងទេដូចចាស់ៗគេដឹងតែបើខ្ញុំខ្ញុំអត់ដឹងទេ

ក៖ ខ្ញុំមិនសួរចេះរាប់ដៃរឆ្នាំចឹងនោះ

ខ៖ លោកគ្រូអត់សួរចេះរាប់ដៃរហោស

ក៖ បាទចុះឪពុករបស់អ៊ុំគាត់បានកើតនៅណាដែរអ៊ុំ កើតនៅនឹងភូមិអីគេ?

ខ៖ គាត់កើតនៅស្រុកនឹងតែម្តង

ក. នៅភូមិអីគេអ៊ុំ?

ខ៖ នៅណុងទាំងអស់ម៉ងទាំងជីដូនជីតាទាំងអស់ម៉ងនឹងនៅភូមិព្រៃរកានឹង

ក៖ អូនៅភូមិព្រៃរកាហោសអ៊ុំ?

ខ៖ នឹងនៅភូមិព្រៃរកា

ក៖ ចុះម្តាយរបស់អ៊ុំអ៊ុំមានដឹងថាគាត់កើតឆ្នាំអីគេអត់អ៊ុំ?

ខ៖ ម្តាយរបស់ខ្ញុំដូចគ្នាម្តាយក្រោយនឹង

ក៖ ម្តាយក្រោយគាត់........

ខ៖ ម្តាយក្រោយនឹងគាត់63ឆ្នាំ

ក៖ គាត់63ឆ្នាំប៉ុន្តែឆ្នាំខ្មែរអ៊ុំមានបានដឹងទេអ៊ុំ?

ខ៖ អត់ដឹងដែរនឹង

ក៖ អ៊ុំអត់ច្បាស់ដែរណអ៊ុំ?

ខ៖ បាទអត់ច្បាស់ដល់ពេលតែអត់ច្បាស់ចឹងខ្ញុំអត់ហ៊ាននិយាយទេ

ក៖ ចុះគាត់កើតនៅណាដែរអ៊ុំ?

ខ៖ គាត់កើតនៅស្រុកណុងដែរនឹង

ក. អូគាត់កើតនៅជិតគ្នាហោស?

ខ៖ គាត់កើតនៅជិតគ្នានៅភូមិតែមួយ

ក៖ ចឹងគាត់កើតនៅភូមិរកាដូចគ្នា ចុះអ៊ុំមានដឹងថាគាត់មានធ្លាប់ប្រាប់ពីប្រវត្តិអីទៅអ៊ុំអត់អ៊ុំ?

ខ៖ គាត់មិនដែរនិយាយទេ

ក៖
ដូចថាឪពុករបស់អ៊ុំគាត់ធ្លាប់បាននិយាយថាកាលពីនៅក្មេងគាត់ធ្លាប់បានធ្វើអីគេដូចជាគាត់ធ្លាប់បានធ្វើអីជាមួយក្រុមគ្រួសាររបស់គាត់ចឹងហាសគាត់មានដែរនិយាយអត់?

ខ៖
អានឹងគាត់ធ្លាប់បាននិយាយប្រាប់ខ្ញុំខ្លះដែរនឹងគាត់ប្រាប់ថាកាលពីដើមគាត់ទៅស៊ីឈ្នួលគេទៅស៊ីឈ្នួលអោយគេនឹងទៅចាំងដីអោយគេនឹងចាំងស្មៅអោយគេនឹងមួយថ្ងៃបានតែ3កាក់ទេ

ក៖ អូបានតែ3កាក់?

ខ៖
នឹងហើយកាលពីជំនាន់ណុងគេចាយកាក់កាលជំនាន់គាត់ហាសបានតែ3កាក់ទេ3កាក់នឹងពេលមកវិញនឹងចូលទិញនេះទិញនោះមកផ្ញើរប្រពន្ធគាត់ហើយនឹងកូនចៅនឹងគាត់ទិញរបស់របរមកប៉ុន្តែអស់លុយតិចនឹងកាលណុងដល់ពេលនេះហើយគាត់បានខ្ញុំនឹងហោកបានខ្ញុំអាយុ13ឆ្នាំដល់ពេលខ្ញុំបានអាយុ13ឆ្នាំនឹងខ្ញុំបានប្អូន2នាក់ហើយ

ក៖ អូអ៊ុំមានប្អូន2នាក់ហើយ?

ខ៖
បាទគាត់ចាប់ផ្តើមធ្លាក់ខ្លួនឈឺហើយបានម្តាយរបស់ខ្ញុំចាប់ផ្តើមចេញរកហើយដល់ពេលនេះទីពីរនាក់ខ្ញុំនឹងអាអញ្ចាត់នឹងអាសំណាញ់យើងនេះយើងយកមកដេរហោសយកទៅអូស
ត្រីចង្វាយើងនឹងត្រីក្រាញ់នឹងត្រីកំភ្លាញអីនឹងយកមកលក់អោយគេមួយគីឡូបានតែមួយកាក់ទេ

ក៖ អូថោកហាសណោះអ៊ុំ?

ខ៖ នឹងហើយមួយគីឡូបានតែមួយកាក់ទេអាត្រីចង្វាយើងនឹងបាន7-8គីឡូក្នុងមួយថ្ងៃ
ថ្ងៃខ្លះ3-

4គីឡូក៏មានដែរចេះតែធ្វើទៅហើយឪរបស់ខ្ញុំចេះតែធ្លាប់ខ្លួនទៅហើយគាត់បានក្អួតឈាម មែនទែនពីព្រោះតែគាត់ធ្វើធ្ងន់ដល់ពេលនេះម៉ែខ្ញុំម៉េចទេទៅបានវល្លិ៍ថ្លុករឺមួយវល្លិ៍ស្អីទេ3មុខរបស់គាត់បានដាំអោយគាត់ហូបនឹងគាត់បាត់ធ្លាក់ឈាម

កៈ ចុះឪពុករបស់អ៊ុំគាត់ប្រកបមុខរបរអីសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខៈ រាល់ថ្ងៃនេះ?

កៈ បាទអ៊ុំ

ខៈ រាល់ថ្ងៃនឹងគាត់មិនប្រកបមុខរបរអីទេគាត់នៅតែផ្ទះនឹងគាត់ធ្វរធាគរាន់បើហើយ

កៈ
ចុះចង់និយាយថាឪពុករបស់អ៊ុំគាត់ជាមនុស្សបែបណាតាំងពីតូចរហូតមកដល់ពេលនេះដូចថាគាត់ស្លូតរឺមួយក៏គាត់កាច់អីចឹងហាសអ៊ុំ?

ខៈ
កូនមិនវៃទេទុកអោយស៊ីបានហើយសិនពេលដែរស៊ីបាយហើយដឹងតែវៃហើយមិនឈាមណាទេខ្នងដឹងតែបែកឈាមហើយ

កៈ ប៉ុន្តែគាត់កាចដែរណាអ៊ុំ?

ខៈ គាត់កាចតែអត់មាត់
តែកូនស៊ីអីស៊ីចុះតែកុំលួចតែបើលួចអាកូននឹងត្រូវហើយដឹងតែត្រូវធ្ងន់ហើយ

កៈ
ចុះម្តាយរបស់គាត់មានធ្លាប់ប្រាប់អីកាលពីគាត់នៅក្មេងទៅអ៊ុំអីទេថាគាត់រកស៊ីអីសំរាប់ចិញ្ចឹមជីវិតដែរហាសអ៊ុំ?

ខៈ គាត់មិនដែរប្រាប់អីទេម្តាយក្រោយនឹងគាត់មិនដែរប្រាប់អីទេ

កៈ តែបើម្តាយមុនគាត់ធ្លាប់បានប្រាប់ហោសអ៊ុំ?

ខៈ ម្តាយមុននឹងខ្ញុំទាន់គាត់តែបន្តិចនឹង

កៈ អូចឹងមានន័យថាអ៊ុំទាន់គាត់តែបន្តិចទេ?

ខ៖
ម្ដាយរបស់ខ្ញុំនឹងកាលពីឆ្នាំ1979នឹងនៅសល់តែ3ថ្ងៃទៀតទេគេបែកហើយគេយកគាត់ទៅសំលាប់ហើយចំណែកប្អូនស្រីរបស់ខ្ញុំចេះក្រឡាប បានយកគ្នាទៅបោកនឹងគល់ត្នោតហើយម្ដាយរបស់ខ្ញុំគេបានអាករគាត់ហើយបានដោតក្បាលគាត់ចឹងទៀតនឹងពីព្រោះម្ដាយរបស់ខ្ញុំគាត់យួនមួយគ្រួសាររបស់គាត់មាន12នាក់គេយកទៅសំលាប់ចោលទាំងអស់

ក៖ អូគ្រួសារម្ដាយរបស់អ៊ុំស្លាប់ទាំងអស់?

ខ៖
នឹងហើយស្លាប់ទាំងអស់ហើយគេបានកប់ដីសើរៗចឹងហោសហើយខ្ញុំបានទៅទាញយកម្ដាយរបស់ខ្ញុំមកនិយាយរួមមួយពូជនឹងទាញឡើងមកទាំងអស់នឹងហើយអ្នកដែរគេសំលាប់នឹងគេបានដើរចេញទៅហើនៅសល់តែ3ថ្ងៃទៀតបែក

ក៖ អូចឹងមានន័យថានៅសល់តែ3ថ្ងៃទៀតចប់ហើយនឹង?

ខ៖
នៅសល់តែ3ថ្ងៃទៀតចប់ហើយម៉ែឪខ្ញុំខំក្រវៀសម៉េចក៏ក្រវៀសមិនរួចដែរធ្វើម៉េចក៏ដោយក៏នៅតែអត់រួចដែរ

ក៖ អូស្ដាយហាសណោះអ៊ុំ

ខ៖
អត់រួចមកចាញ់ត្រង់ថាឪរបស់ខ្ញុំមកចាញ់នយោបាយគេត្រង់ថាអាសឿហែងទៅមើលគេស្ដារព្រែកបន្តិចទៅទៅតែមួយម៉ោងទេមកវិញហើយឪខ្ញុំបានចេញផុតតែមួយគីឡូដីបានយកមួយពូជទៅសំលាប់ចោលទាំងអស់គ្មានទុកមួយទេ
តែឥឡូវពេលបច្ចុប្បន្ននេះអាអ្នកនៅជិតៗភូមិខ្ញុំនឹងគេហៅខ្ញុំថាអាយួនតា
តែភាសាយួនតែមួយម៉ាតក៏ខ្ញុំអត់ចេះដែរម៉ែខ្ញុំយួនមែនតែឪខ្ញុំខ្មែរ

ក៖ តែអ៊ុំឯងត់ចេះយួនទេ?

ខ៖ មួយម៉ាត់ក៏ខ្ញុំមិនចេះដែរ

ក៖ ចុះម្ដាយរបស់អ៊ុំគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជិវិតដែរអ៊ុំ?

ខ៖ ម្ដាយរបស់ខ្ញុំសព្វថ្ងៃនឹងគាត់ចិញ្ចឹមតែជ្រូក

កៈ អូគាត់ចិញ្ចឹមជ្រូកហោសអ៊ុំ?

ខៈ គាត់ចិញ្ចឹមជ្រូក មាន់ ទា

កៈ ចឹងគាត់មានកសិដ្ឋានចិញ្ចឹមរឺមួយក៏គាត់ចិញ្ចឹមលក្ខណៈថាល្មមអ៊ុំ?

ខៈ គាត់ចិញ្ចឹមល្មមនឹងតែគាត់វៃអាសំណាញ់យើងនឹងដោយខាន់របស់គាត់

កៈ អូចឹងមានន័យថាគាត់បើកជាកសិដ្ឋានមួយហើយ

ខៈ អត់អត់មានទេ

កៈ ប៉ុន្តែគាត់បើកលក្ខណៈថាបើកតូច?

ខៈ អត់ទេគាត់ធ្វើសំរាប់ទានឹងតែទាដោយទា នឹងមាន់ដោយមាន់ទៅ

កៈ តែគាត់ជាមនុស្សបែបណាដែរអ៊ុំគាត់កាច់រឺមួយក៏គាត់ស្លូតអ៊ុំ?

ខៈ ម្ដាយរបស់ខ្ញុំគាត់ស្លូតណាស់

កៈ អូគាត់ស្លូតហោស?

ខៈ ម្ដាយរបស់ខ្ញុំស្លូតណាស់

កៈ ចុះកាលអ៊ុំនៅជាមួយពួកគាត់អ៊ុំមានដែរមានដាច់រឿងអីជាមួយពួកគាត់ទេអ៊ុំ ដូចជាធ្លាប់ធ្វើអីគេជាមួយនឹងឪពុកម្ដាយរបស់អ៊ុំចឹងហាស?

ខៈ ទេខ្ញុំដូចជាមិនដែរទេលោកគ្រូ

កៈ
អត់ដែរមានលក្ខណៈថាទៅស្រែអីជាមួយគាត់អត់ដែរមានថាធ្វើអីមួយជាមួយគាត់ទេអ៊ុំ?

ខៈ អូមានលោកគ្រូមានចេះឪពុករបស់ខ្ញុំគាត់បបួលទៅភ្ជួរនោះ

កៈ បាទអ៊ុំមានអីគេខ្លះដែរអ៊ុំ?

ខៈ
ខ្ញុំបានខឹងនឹងអាពួកម៉ាក់ថាវត្តហែងតិចទៀតដល់ហើយគេហៃតាខិណ្ឌានោះអានឹងលក្ខណៈថាគេបានបែកអីអស់ហើយកាលពីជំនាន់ឆ្នាំ1983-1984អីហោស

កៈ អូពេលណុងបែកអាពតហើយណអ៊ុំ?

ខៈ
បែកហើយគេថាអញ់ទៅនោះទៅដែរបានដឹកក្របីលីនង្គ័លឪទៅដល់ស្រែហើយខ្ញុំបានដឹកគោយកទៅអោយគាត់ពេលដឹកចឹងទៅដល់ចុងកន្ទុយកំពុកវារៀងទេរមកចឹងវាមានច្រើនហោសបានចាប់ចង់ជិតៗដល់ច្រមុះគោវាស៊ីមានបានស្អីបើវាត់ឡើងដល់លើហើយច្រមុះវាទៅលើទាំងអស់ ត្រូវ4ប្រណ្ឌង អូ4ខ្សែទៃឡើងបែកជុំវិញខ្លួនខ្សែទៃធំជាងនឹង

កៈ អូបាទអ៊ុំ

ខៈ
ត្រូវ4ខ្សែទៃអាលក្ខណះត្នោតយើងមិនធម្មតាណាឡើងបែបឈាមដូចគេចងរឹតពីកាលណាមកចឹង

កៈ គោហោសអ៊ុំ?

ខៈ ឪវៃមិនមែនគោអី

កៈ ឪពុករបស់អ៊ុំវៃអ៊ុំហោសអ៊ុំ?

ខៈ
នឹងហើយឪមកតាឪមកតាឪឃើញគោពេលដែរខ្ញុំទៅដល់ផ្ទះនឹងខ្ញុំងូតទឹកប្រហែលម៉ោង7ព្រឹកនឹងគ្មានទេលេងពីក្រោមម៉ង
ខ្ញុំគ្មានដឹងថាឪទៅតាមណាឪជេថាឪអោយហែងដឹកគោយកទៅភ្ជួរហែងយកគោទៅចងហីម៉េចឪអែងដឹងខ្ញុំបានសើចដាក់ឪទៀតហើយឪប្រាប់ថាចុះបើអញ់ទៅឃើញខ្ញុំអត់មានស្រក់ទឹកភ្នែកមួយតក់ទេលក្ខណះថាអាខោត្រឹមនឹងហោសអាខោបារាំងគេនោះដើរទៅទាញគោមកដឹកភ្ជួរខ្លួនអែងនឹងហើយតាំងពីនឹងមកមិនមានបញ្ហាអីទាំងអស់ទេ

កៈ
ចុះអ៊ុំមានចងចាំយាយតាខាងម្តាយរបស់អ៊ុំអត់ម្តាយឪពុករបស់ម្តាយអ៊ុំហាសអ៊ុំបានស្គាល់ឈ្មោះគាត់អត់អ៊ុំ?

ខៈ អើរនៅតា

កៈ ចុះតាឈ្មោះអីគេដែរអ៊ុំ?

ខ៖ តាមានឈ្មោះឈិន ងង

ក៖ ចុះតានៅរស់សព្វថ្ងៃមែនទេអ៊ុំ?

ខ៖ តាបានស្លាប់បាត់ហើយ

ក៖ តាគាត់ស្លាប់បាត់ហើយចុះតាគាត់អាយុប៉ុន្មានអ៊ុំមានដឹងអត់អ៊ុំ?

ខ៖ តាខ្ញុំអត់ដឹងទេប្រហែលមកដល់ឥឡូវគាត់100ឆ្នាំជាងហើយមើលទៅ

ក៖
គាត់ប្រហែលជា100ឆ្នាំជាងហើយណោះអ៊ុំចុះគាត់បានកើតនៅណាអ៊ុំមានបានដឹងអត់អ៊ុំ?

ខ៖ គាត់កើតនៅព្រៃអង្គរ

ក៖ អូគាត់កើតនៅព្រៃអង្គរហោស?

ខ៖ សាច់ញ្ញាតិតារបស់ខ្ញុំនៅណុងទាំងអស់បច្ចុប្បន្នពួកគាត់នៅទីនោះទាំងអស់នឹង

ក៖ អូខាងយាយក៏នៅទីនោះដែរ?

ខ៖
ពេលដែរសំភាសន៍នោះថាបងអែងទៅនៅណាខ្ញុំទៅនៅណុងហើយឪរបស់ខ្ញុំគាត់ថាខ្ញុំទៅនៅខាងខ្មែរ ហើយម៉ែខ្ញុំមានមីងម៉ា
អីមួយពូជនឹងនៅណុងទាំងអស់នឹងមកតាមឪរបស់ខ្ញុំនឹងមកនៅបានប្រម៉ានប្រហែលជាមួយឆ្នាំជាងនឹងមិនគួរសោះនៅតែ3ថ្ងៃទៀតនៅមិនបានខ្ញុំនៅតែគិតរាល់ថ្ងៃនឹងគាត់ទ្រាំបានយូរហើយចុះនៅតែ3ថ្ងៃទៀតគាត់ទ្រាំមិនបានធ្វើបាប់គាត់ដល់ថ្នាក់នឹង

ក៖ ចុះជីដូនជីតាខាងឪពុកអ៊ុំមានស្គាល់ឈ្មោះពួកគាត់ទេ?

ខ៖ នឹងស្គាល់ពួកគាត់ទាំងអស់

ក៖ ពួកគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖ ខាងឪពុករបស់ខ្ញុំនឹងឈ្មោះសុខនឹងត្រកូលរបស់គាត់ហាសគឺឈ្មោះសុខ ឈឹម

ក៖ អូឈ្មោះសុខ ឈឹម ចុះតាវិញអ៊ុំ?

ខ៖ ចំណែកតាឈ្មោះសូ អៀង

ក៖ សូអៀង ចុះគាត់កើតនៅឆ្នាំអីអ៊ុំមានដឹងអត់?

ខ៖ បើគ្រូអែងនិយាយពេលដែរគាត់ស្លាប់ខ្ញុំដឹងអាយុ

ក៖ ចុះគាត់បានស្លាប់នៅឆ្នាំណាដែរអ៊ុំ?

ខ៖ តារបស់ខ្ញុំស្លាប់នៅឆ្នាំ1990ហោសចឹងហើយនៅឆ្នាំ1990

ក៖ ចុះកាលពីគាត់ស្លាប់គាត់នៅអាយុប៉ុន្មានដែរអ៊ុំ?

ខ៖ គាត់អាយុចិតជាង

ក៖ អូគាត់អាយុចិតជាងចឹងមានន័យថាបើមកដល់ឥឡូវគាត់ប្រហែលជិត100ឆ្នាំហើយមែនទេ?

ខ៖ ជិតអីមានតែជាង100នឹងហើយ

ក៖ នឹងហើយអ៊ុំ

ខ៖ ហើយយាយរបស់ខ្ញុំបានស្លាប់នៅឆ្នាំ1981

ក៖ អូស្លាប់នៅឆ្នាំ1981

ខ៖ យាយខ្ញុំបានស្លាប់នឹងនៅអាយុ84ឆ្នាំគាត់អាយុបងតារបស់ខ្ញុំ

ក៖ អូចឹងមានន័យថាគាត់ចង់100ហើយលក្ខណះថាគាត់100ជាងហើយចឹងនោះ?

ខ៖ នឹងហើយគាត់អាយុ100ឆ្នាំជាងផង

ក៖ ចុះអ៊ុំមានដឹងថាគាត់បានកើតនៅណាទេទាំងតាទាំងយាយ?

ខ៖ គាត់បានកើតនៅនឹងម៉ង

ក៖ អូគាត់បានកើតនៅណុងម៉ងនៅណុងទាំងអស់គ្នាម៉ង

ខ៖ នៅណុងទាំងអស់គ្នា
ជេកបានខ្ញុំហ៊ានអះអាងពីព្រោះខ្ញុំបានបើភ្នែកឡើងដឹងក្ដីឡើងខ្ញុំបានមើលទឹកដីភូមិគាត់

នៅនឹងហើយខ្ញុំបានសួរមីងខ្ញុំទេខ្ញុំមិងខ្ញុំកូនគាត់បងគេនឹងខ្ញុំសួរគាត់ថាមីងស្រុកកំណើតរបស់មីងអែងនៅណាអញនៅជនអញនៅភូមិអញកើតនៅនឹងទាំសងដូនតាបានខូជឿនឹង

ក៖ ចុះក្រុមគ្រួសាររបស់មកនៅទីក្រុងភ្នំពេញនឹងយូនៅអុំ?

ខ៖ ខ្ញុំនឹងមែន?

ក៖ បាទអុំ?

ខ៖ ខ្ញុំមកនៅនឹងតាំងពីឆ្នាំ1993

ក៖ អូតាំងពីឆ្នាំ1993រហូតមកដល់ឥឡូវហោស?

ខ៖ តាំងពីឆ្នាំ1993ពេលដែរខ្ញុំមានការរស់អីនឹងហោកចូលឆ្នាំចូលអីចឹងទៅបានទៅ

ក៖ ចឹងមានន័យថាចង់25ឆ្នាំហើយណោះអុំ?

ខ៖ ចូលហើយ

ក៖ នឹងហើយអុំ25ឆ្នាំម៉ង

ខ៖ បាទត្រូវហើយចូលហើយតាំងពី1993មក

ក៖ ឆ្នាំ1993រហូតមកដល់ឥឡូវ2018វា25ឆ្នាំហើយ

ខ៖ អូនឹងហើយយូដែរហើយ

ក៖ អូឆ្នាំ1993ខ្ញុំបានកើតបាន2ឆ្នាំខ្ញុំកើតនៅឆ្នាំ1991

ខ៖ បាទត្រូវហើយ

ក៖ ចុះអុំបងប្អូនណាដែររស់នៅក្រៅពីស្រុកខ្មែរទេអុំ?

ខ៖ អត់មានទេ

ក៖ ដូចជានៅវៀតណាមអីចឹងហាស?

ខ៖ អត់មានទេ

ក៖ អូអត់មានទេណ ចុះភរិយារបស់អុំសព្វថ្ងៃនឹងគាត់មានឈ្មោះអីគេដែរអុំ?

ខ៖ ប្រពន្ធរបស់ខ្ញុំសព្វថ្ងៃនឹង?

ក៖ បាទអ៊ុំភរិយាអ៊ុំហាស?

ខ៖ គាត់ឈ្មោះយស ណូ

ក៖ អូគាត់មានឈ្មោះថាយស ណូ ចុះអ៊ុំរៀបអាពាហ៍ពិពាហ៍នៅពេលណាដែរអ៊ុំ?

ខ៖ ខ្ញុំបានរៀបនៅឆ្នាំ1990 ខែ1 ថ្ងៃទី17

ក៖ អូអ៊ុំបានចាំហោស?

ខ៖ អានឹងចាំកត់នៅនឹងទាំងអស់អានឹងខ្ញុំចាំ

ក៖ ចុះអ៊ុំរៀបអាពាហ៍ពិពាហ៍ណាវិញអ៊ុំ?

ខ៖ ខ្ញុំបានរៀបអាពាហ៍ពិពាហ៍នឹងនៅខាងប្រពន្ធ

ក៖ អូនៅខាងប្រពន្ធរបស់អ៊ុំនៅស្វាយរៀងនឹងហោស?

ខ៖ បាទនៅស្វាយរៀងនឹង ហើយភូមិនៅជិតគ្មានឹងព្រៃរកា នឹងចំបកនឹងជិតគ្នានឹងនេះក្មួយ

ក៖ អូក្មួយហោស ចុះនៅពេលដែរអ៊ុំបានរៀបអាពាហ៍ពិពាហ៍នឹងតើអ៊ុំជាអ្នករៀបចំដោយចិត្តឯងរឺមួយក៏ឪពុកម្ដាយជាអ្នករៀបចំអោយដែរអ៊ុំ?

ខ៖ គឺព្រះជាអ្នករៀបចំអោយ

ក៖ អូព្រះជាអ្នករៀបអោយហោស?

ខ៖ នឹងហើយអត់មានបានប្រឆាំងព្រះថាអូសរំលងចេះរឺរំលងចុះអីអត់ហើយប្រពន្ធមានមួយនឹងអត់លែងទៅណាបានទេ

ក៖ កាលពីអ៊ុំទៅចូលស្ដីដណ្ដឹងអ៊ុំស្រីនឹងដូចជាអ៊ុំមានជាជំនូនអីអត់លក្ខណះថាបណ្ណាការហោស?

ខ៖ ទេកាលពីជំនាន់ណុងគេបានយក7ម៉ឺន

ក៖ អូគេយក7ម៉ឺនហោស?

ខ៖ បាទគេយក7ម៉ឺននឹងសំរាប់សំលៀកបំពាក់គេនឹង

ក៖ បាទអ៊ុំមានអី

ខ. ហើយឪក្មេកខ្ញុំនឹងកុំអីក៏មិនដឹងដែរគាត់នឹងជាបងធំមឪរបស់ខ្ញុំគាត់នឹងរាក់ទាក់គ្នាណាស់ ហើយបាយម្ហូបនឹងនៅលើខាងខ្ញុំទាំងអស់នឹង

ក. អូចុះអ៊ុំអាចប្រាប់ខ្ញុំបានទេថានៅពេលណាដែរអ៊ុំបានជួបជាមួយភរិយាអ៊ុំហើយពេលណាដែលដែរអ៊ុំបានស្រលាញ់គ្នាជាមួយគាត់ដែរលក្ខណះថាមានស្នេហាជាមួយគ្នាអីចឹងហាស

ខ៖ នៅក្នុងខែនឹង ថ្ងៃនឹង

ក៖ ហើយនៅថ្ងៃណាដែរ?

ខ៖ បានតែ3ថ្ងៃទេ

ក៖ ហើយក៏បានចូលម៉ង?

ខ៖ ស្រលាញ់ទាំតែឃើញម្នាក់មួយទៀតឈ្មោះណាគ្រីនឹងនៅជិតនឹងនៅទល់មុខនឹងខ្ញុំបានមើលទៅម្នាក់នឹងចេះតែញញឹមដាក់ខ្ញុំខ្ញុំបានហៅថាជួយធ្វើមេអណ្តើកអោយមួយប្រពន្ធខ្ញុំនឹងអោយទាក់ទងអោយខ្ញុំនឹងគេនិយាយវិញមានអីហើយដល់ពេលនេះទៅវាបានដើរទៅហៅមកណោះគាត់ហៅអែងហោស ហៅធ្វើអីហើយខ្ញុំអោយណាគ្រីនឹងនៅជិតនឹង

ក៖ បាទអ៊ុំមានអីទៀត?

ខ៖ ហើយត្រូវជាបងប្អូនគ្នាទៀតអោយគេទិញមាន់មួយទិញមកស្ងោរពេលស្ងោរនឹងខ្ញុំក៏ថាទៅខ្ញុំថាហ្វបមាន់មាន់ស្ងោរកុំអោយស្ងោរមនុស្ស បើមានចិត្តស្ងោរបានក៏ស្ងោរទៅ ហើយខ្ញុំបានប្រាប់ថាស្អែកខ្ញុំអោយឪរបស់ខ្ញុំមក

កៈ អូអោយខូលស្តីអ៊ុស្រី?

ខៈ
បាទនឹងហើយបើខ្ញុំបានប្រាប់ណាគ្រីនឹងថាបើខ្ញុំស្ញោរម្នាក់នឹងមិនបានខ្ញុំនឹងស្ញោរមេអណ្តើកនឹងតែម្តងស្អែកឡើងខ្ញុំអោយឪខ្ញុំមកត្រូវខែឆ្នាំត្រូវគ្នា

កៈ អ៊ុក៏បានការទៅណអ៊ុ?

ខៈ នឹងការល្មម អត់មានថាម៉ែឪទៅតាមទទឹងទទែងអិអត់មានទេ

កៈ ហើយខាងស្រីគេបានព្រមទៅ?

ខៈ នឹងហើយព្រមដូចគ្នាព្រមបានដេញខែ ឆ្នាំយកតែម្តង

កៈ ចុះអ៊ុចេះអានរឺមួយក៏ចេះសរសេរអក្សរខ្មែរបានល្អប៉ុណ្ណាដែរអ៊ុ?

ខៈ ខ្ញុំរៀនបានថ្នាក់ទី3

កៈ អូអ៊ុបានរៀននៅថ្នាក់ទី3ហោសអ៊ុហោស?

ខៈ បាទលោកគ្រូ

កៈ ថ្នាក់ទី3រៀននៅសាលាបឋមមែនទេអ៊ុ?

ខៈ កាលឆ្នាំ82ខ្ញុំបានឈប់រៀន ឆ្នាំ82ចូល83ហើយនៅខែ6ថ្ងៃទី15

កៈ អ៊ុបានឈប់រៀនហោស?

ខ. ខ្ញុំខឹងគេដេញចាប់ពុកខ្ញុំពេកកាលពីពលករហោសខ្ញុំថាអឺមបងអើយខ្ញុំនៅប៉ុណ្ណឹងហោកមិនបាច់ទេមិនបាច់ដើរចាប់គាត់ទេគាត់ចាស់ហើយបន្លារំចេកហាសលោកឪរបស់ខ្ញុំគាត់បានលោតផ្លោសពេលព្រលឹមឡើងនឹងកូនៗម៉ែខ្ញុំបានដក់អោយឈាមរហាមពេញនឹងខ្ញុំខឹងពេកទឹកភ្នែកមួយតក់ក៏ខ្ញុំមិនស្រកផងខ្ញុំបានថាមិនអីទេបងឆ្លកអែង

កៈ មានរឿងអីជាមួយគ្នាមែនអ៊ុ?

ខ
ពេលនោះខ្ញុំចូលភូមិស្អែកឡើងខ្ញុំអត់ទៅរៀនទេខ្ញុំសួរគេថាបងៗប៉ុនខ្ញុំគេយកទេហើយគេថាងាប់ហើយក្បាលចឹងចក់អាណាគេយក

ហែងទៅឃុំគាត់ថាហែងនេះហាគ្រាន់តែលីតែស្នូរនឹងក៏ស្លាប់ដែរ ខ្ញុំបានទៅស្រុកហើយស្រុកថាបើអូនអែងក្លាហានទៅឡើងទៅខេត្តទៅ ពេលដែរខ្ញុំទៅខេត្តខេត្តបញ្ជូនទៅទៀតប្រាប់ខ្ញុំទៀតថាបើអូនអែងក្លាហានខាងចឹងមែនអូនអែងទៅចំការខ្មុរនៅរមាសហែកនឹងទៅកន្លែងរឹករើនអូនអែងទៅសក់គេតិចទៅបានចូល ហើយខ្ញុំថាមែនទេពូហើយគាត់ថាមែនតាហើយខ្ញុំបានមកដល់ផ្ទះហើយខ្ញុំប្រាប់ឪរបស់ខ្ញុំថាឪៗខ្ញុំសុំឪអែងទៅលេងរមាសហែក3ថ្ងៃបានហើយមិនបាច់ទេឪខ្ញុំបានសុំគ្រូហើយៗ

កៈ ចឹងអុំឈប់រៀនហើយចឹង?

ខ.
មិនទេគឺឈប់តែម្តងនឹងយប់នឹងលោកគ្រូខ្ញុំនិយាយក្នុងនឹងលោកគ្រូអែងថតទៅខ្ញុំបានលួចលុយឪកាលណុងមានអាក្បាលសឹងចងអាវឡើងដាក់នៅក្នុងអាវលោកគ្រូអែងគិតមើលទៅមួយសែនប្រាំមួយម៉ឺនតិចទៅហោស

កៈ អូច្រើនហាសណា?

ខៈ
មានមួយសែនប្រាំមួយម៉ឺនលុយរបស់ឪពុកខ្ញុំគាត់មានជាងមួយលានតែខ្ញុំយកតែប៉ុណ្ណឹង

កៈ ចុះអុំបានយកទៅធ្វើអីគេវិញអុំ?

ខៈ ខ្ញុំបានយកទៅសកគេ

កៈ អូអុំបានយកទៅសកគេហោស?

ខ.
នឹងមិនទាន់ចប់ទេតិចទៀតបានលោកគ្រូអែងដឹងហេតុតែខ្ញុំចង់អោយបានចូលនៅម៉ោង4ទាបភ្លឺលោកគ្រូអែងខ្ញុំថាពូពូនឹងជាពូនៅខាងឪពុករបស់ខ្ញុំនឹងខ្ញុំបានសួរគាត់ថាទៅរមាសហែកយកម៉ានដែរពូគាត់ប្រាប់ខ្ញុំថាអោយមួយរៀលមកគាត់ថាហែងមានលុយទេទាលតែអោយលុយមុនបានជឿ

កៈ អូពូទៅរមាសហែកហោសពូ?

ខ.
នឹងហើយខ្ញុំបានអោយលុយឧបខ្ញុំលឿនហាសពេលដែរខ្ញុំទៅដល់ខ្ញុំបានសួរគេខ្ញុំទាហ៊ាននឹ

ងបងៗកន្លែងដែរគេចុះឈ្មោះធ្វើជាទាហ៊ាននៅកន្លែងណាដែរគាត់ប្រាប់ថាហីកន្លែងនឹង ហើយខ្លាំងនៅប្រខ្មែរនឹងហើយហែងចង់ទៅណាបានចង់រៀនទាហ៊ាននឹងហែងមាន50រៀលទេ កាលណុងក្រដាស50រៀលប៉ុននេះអាព៌ណាក្របាមហាស

ក៖ អូពេលនោះលុយថ្លៃ?

ខ. ហីលុយវាថ្លៃដែរនឹងហើយខ្ញុំប្រាប់គាត់ថានេះខ្ញុំជូនពូ100រៀលហើយគាត់និយាយអញ់ទៅផឹកស្រាសិនខ្ញុំស្មានតែនិយាយលេងពួកគាត់ទាំង3នាក់ចុះមកហែកនៅនឹងមួយទៅពីរនាក់នៅទល់មុខចឹងឆ្លងថ្នល់ទៅដល់ហើយខ្ញុំបានប្រាប់ថាពូអែងចង់ហូបប៉ុន្មានក៏ហូបទៅគាត់ដាក់មែនម្នាក់អស់3ចានស្រាអស់កន្លះលីត្រតោះទៅវិញពេលមកដល់ខ្ញុំប្រាប់ថាពូខ្ញុំជូនម្នាក់50រៀលពេលដែរផឹកស្រានឹងអស់តែម្នាក់មួយរៀលទេតែខ្ញុំជូនពូម្នាក់50រៀលគេបានដាក់ខ្ញុំជាទាហានសេរីតែម្ដង ជាទាហ៊ានស្ម័គ្រចិត្តសេរី

ក៖ អូពួកគាត់ជួយពូបាន?

ខ៖ នឹងមេប្រកាន់ប៉ុស្តិ៍ដាក់ថាទាហ៊ានសេរីហើយគេថាខ្ញុំចង់ចេញដើរទៅណាក៏ទៅទៅនៅឆ្នាំ1983 ខែ9ថ្ងៃទី1ត្រូវក្មួយអែងមកដល់ពីព្រឹកមកដល់ពីព្រឹកគេបញ្ចូលថ្ងៃនឹងពេលដែរខ្ញុំទៅដល់មានអីគេអោយកាំភ្លើងស្ពាយអាកាអាដងវែងនឹងអូសដី

ក៖ អូអូសដីទៅម៉ងអុំ?

ខ៖ បើពីប្រធានរឹករីននឹងគេបានយកអាស្វ័យបទអោយអាស្វ័យបទអានឹងចង់ដល់ដីទៀតទាល់តែដាក់ទទឹងចេះហើយខ្ញុំនិយាយថាបងបងទៅតឡូវហោសដាក់ស្បែកជើងអើយច្រើនហើយដាក់ស្រាមួយកានទៅពីរកានទៅបើបងអែងចូលចិត្តហូបបងអែងទិញម្ហូបទិញអីខ្ញុំទិញអោយគាត់ចេញឡានអោយទៅដល់មុខកងត្រួលព្រែកភ្នៅគ្មានទេស្បែកជើងទំរូតផ្ទុះៗនឹងឬស្សីនឹងពូៗស្រវឹងអស់ហើយដល់ពេលឆ្នាំ1988គេបានដាក់ជនប៉ះប៉ោលគង់ធូច្បាប់ទៅលេងស្រុកមួយខែទាហ៊ានសេរីកាលណុងខ្ញុំឡើងបានទាហ៊ានគពេលមកដល់ស្រុកមកវិញមួយសារទៀតបានមួយឆ្នាំមកវិញនាំប្រពន្ធខ្ញុំទៅមានប្រពន្ធនៅបាត់ដំបងខ្ញុំមានកូនមួយបានចោលគេនៅណុងមិនទាន់ការ

កៈ
ចុះសំរាប់អ៊ុំកាលអ៊ុំរៀននៅសាលាបឋមនឹងអ៊ុំបានរៀននៅសាលាបឋមសិក្សាណាដែរអ៊ុំមាននៅចងចាំឈ្មោះទេ?

ខៈ រៀននៅសាលាឃុំឈើទាលនឹង

កៈ អូរៀននៅសាលាឃុំឈើទាលចឹងម៉ងហោសអ៊ុំនៅខេត្តស្វាយរៀង?

ខៈ នឹងហើយនៅខេត្តស្វាយរៀងនឹង

កៈ
ចុះអ៊ុំមានធ្លាប់មានមិត្តភក្តិស្និទ្ធិស្នាលណាដែរធំធាត់មកជាមួយគ្នាទេលក្ខណៈថាជាអនុស្សាវរីយ៍អីជាមួយគ្នាចឹងហាស?
ខៈ កាលពីខ្ញុំនៅរៀនខ្ញុំមានច្រើនណាស់លោកគ្រូ

កៈ អូមានច្រើនហោសអ៊ុំអាចរៀបរាប់2-3-4-5នាក់អីបានទេ?

ខៈ បានត្រឹម2-3នាក់អីនឹង

កៈ ចុះពួកគាត់មានឈ្មោះអីគេខ្លះដែរទៅអ៊ុំ?

ខៈ ឈ្មោះដែរខ្ញុំរាប់ជាងគេមាន4នាក់

កៈ អូដែរស្និទ្ធស្នាលជាងគេហោសអ៊ុំ?

ខៈ ដែរស្និទ្ធិស្នាលមានស្រី3នាក់ប្រុស1នាក់ទៀត

កៈ អូស្រី3នាក់នាក់ ប្រុស1នាក់

ខៈ ទេមិនស្រលាញ់អីទេ

កៈ លក្ខណៈថាជារាប់អានណាអ៊ុំ?

ខៈ មានអីធ្វើជាមួយគ្នា មានអីហូបហូបជាមួយគ្នាស្មោះត្រង់មែន

កៈ មានឈ្មោះអីគេដែរអ៊ុំ?

ខៈ មុនគេមានឈ្មោះសុខស៊ីណា

កៈ សុខស៊ីណាណាអ៊ុំ?

ខៈ មួយទៀតចាន់ស៊ីណាបងប្អូន2នាក់នឹងគឺកូនភ្លោះ2នាក់នឹង រស់ចាន់ណា ហើយអាប្រុសនឹងចាន់ភី នឹងតែ4នាក់នឹងដែរខ្ញុំរាប់ស្និទ្ធិស្នាល

កៈ ចុះអ៊ុំគិតថាអ៊ុំមានអនុស្សាវរីយ៍អីដែរអ៊ុំគិតថាធ្វើអីជាមួយនឹងពួកគាត់ជាមួយនឹងមិត្តភក្តិស្និទ្ធិស្នាលរបស់អ៊ុំហាសអ៊ុំ?

ខៈ អត់ដែរមានអីទេ

កៈ ចឹងអត់ដែរមានទេ?

ខៈ ដឹងតែដើរលេងមានបានអីហូបហូបជាមួយគ្នាចឹងទៅ

កៈ ចុះអ៊ុំធ្លាប់បានធ្វើការនៅវាលស្រែរឺមួយក៏ស្រែចំការអីអត់អ៊ុំ?

ខៈ មានតែដក់ស្ទូងនឹង

កៈ អូដក់ស្ទូងហោស ចុះអ៊ុំមានធ្លាប់បើកអាជីវកម្មលក់ដូររឺមួយមានចិញ្ចឹមសត្វអីទេដូចជាចិញ្ចឹមមាន់ ចិញ្ចឹមទា ចិញ្ចឹមជ្រូក ចិញ្ចឹមគោ?

ខៈ ចិញ្ចឹមបានតែចិញ្ចឹមតិចតួចគោ មាន់ ទា ជ្រូកអីនឹងបានគ្រាន់តែយើងហូបនឹង

កៈ ចុះអ៊ុំធ្លាប់បានធ្វើការងារអីគេខ្លះនៅក្នុងជីវិតរបស់អ៊ុំ?

ខៈ មុនដំបូងខ្ញុំច្រើនណាស់លួមបានកូនធំមុនដំបូលខ្ញុំលីដែកស៊ីម៉ង

កៈ អូបាទអ៊ុំ

ខៈ មួយប៉ាវបានតែ20រៀលមួយថ្ងៃខ្ញុំបានតែ7-8ពាន់ទេមិនហ៊ានហូបទេទុកអោយកូនពោះខ្ញុំនោះក្ងរមិនហ៊ានស៊ីទេពីព្រោះខ្លាចប្រពន្ធកូនអត់ស៊ីបាយកញ្ចប់ប៉ុណ្ណឹងហូបមិនអស់ទៀត

កៈ ចុះតាំងពីក្មេងរហូតមកដល់ឥឡូវអ៊ុំគិតថាជីវិតរបស់អ៊ុំបានផ្លាស់ប្តូរអីគេខ្លះដែរអ៊ុំ?

ខៈ ខ្ញុំផ្លាស់ប្តូរដែរទាល់តែខ្ញុំផ្លាស់ប្តូរនឹងឈឺតែម្តងនឹង

កៈ អូពីក្មេងអ៊ុំមិនសូវអីទេតែឥឡូវអ៊ុំឈឺ?

ខៈ
ឥឡូវឈឺច្រើនតាំងពីក្មេងរហូតមកដល់អាយុ50គត់នេះខ្ញុំមិនដែរចេះឈឺឈឺចាប់អីក៏ដោយ ទើបតែមកនឹងនេះធ្វើការធ្ងន់ៗខ្ញុំបើធ្វើធ្ងន់ពេកលោកគ្រូអើយ

កៈ ចុះម្ហូបអីដែរអ៊ុំចូលចិត្តជាងគេអ៊ុំ?

ខៈ ខ្ញុំបើនិយាយអោយសមញ្ញទៅ...

កៈ លក្ខណៈថាដូចជាស្លម្ជូរ កកូរដូចនាអីចឹងហាស?

ខៈ អើរបើពីរនឹងត្រូវម្ជូរ នឹងកកូរ

កៈ ចុះការីហោសអ៊ុំ?

ខៈ បើការីអត់ទេ

កៈ ចឹងការីអត់ទេណាអ៊ុំ?

ខៈ ហើយមួយទៀតគឺញ៉ាំស្ដៅ លក្ខណៈថាញ៉ាំស្ដៅប៉េងប៉ោះអីនឹងត្រូវហើយ

កៈ បាទអ៊ុំ

ខៈ នឹងហូបមិនទាន់ខ្ញុំទេ

កៈ ចុះល្បែងប្រជាប្រិយ៍អីដែរអ៊ុំគិតថាចូលចិត្តលេងតាំងពីតូចដូចជាបោះអង្គុញ ទាញព្រាត លាក់កន្សែង ដែរអ៊ុំគិតថាចូលចិត្តលេងតាំងពីតូច?

ខៈ អូខ្ញុំមិនចូលចិត្តលេងទេ

កៈ អូអ៊ុំមិនចូលចិត្តលេង?

ខៈ ល្បែងប្រជាប្រិយ៍លាក់កន្សែង ទាញព្រាត ប៉ោះអង្គុញអត់ចំណូលនឹងគេ

កៈ អូអ៊ុំអត់ចំណូលទេ?

ខៈ ប៉ុន្តែបើអោយដើរលេងរាំ វៃកអីអានឹងចូលចិត្ត ប៉ុន្តែបើអោយចោលឈូង ប៉ោះអង្គុញ ទាញព្រាតអីនឹងមិនចំណូលទេតែបើអោយឈរមើលគេឈរ

កៈ អូឈរមើលគេហោស?

ខៈ ឈរមើលគេបើគេសើចសើចនឹងគេ តែបើអោយគេទាញចូលខ្ញុំមិនចូលទេ

កៈ
ចុះអ៊ុំមានបទចំរៀងណាដែរអ៊ុំគិតថាអ៊ុំរៀនច្រៀងតាំងពីក្មេងរហូតមកដល់ពេលនេះហាស?

ខៈ អត់ចេះសោះម៉ង

កៈ តែអ៊ុំចូលចិត្តស្តាប់បទចំរៀងទេ?

ខៈ បើស្តាប់លេខសួរទៅបើក ឃើញខ្ញុំនៅក្រៅចឹងទេតែបើខ្ញុំនៅក្នុងផ្ទះនៅ

កៈ ស្តាប់ចំរៀងរាល់ថ្ងៃ?

ខៈ អើយតែសៅរ៍ នឹងអាទិត្យអោយតែចេញបទចំរៀងមកកូនឈប់ទុកអោយឪ

កៈ ចំរៀងអីគេអ៊ុំចំរៀងខ្មែរ?

ខៈ ចំរៀងខ្មែរយើងនឹង

កៈ ចំរៀងសម័យរឺមួយក៏ចំរៀងបុរាណ?

ខៈ ចំរៀងសម័យយើងនឹង

កៈ អូអ៊ុំចូលចិត្តចំរៀងសម័យ

ខៈ នឹងហើយចូលចិត្តចំរៀងសម័យ

កៈ ចុះអ៊ុំរឺមួយមាននរណាគេម្នាក់ចេះលេងឧបករណ៍ភ្លេងទេអ៊ុំ?

ខៈ អត់ទេ

កៈ អត់ទេណា
ចុះអ៊ុំផ្ទះរបស់អ៊ុំមានលក្ខណះបែបណាតាំងពីក្មេងរហូតមកដល់ឥឡូវថាពីមុនផ្ទះម៉េចទៅ
ឥឡូវផ្ទះម៉េចទៅចឹងហាសអ៊ុំ?

ខៈ កាលផ្ទះនៅស្រុកនឹងផ្ទះតូចតៀមយើងនឹងចង់បានខ្ពស់តែមិនមានលុយធ្វើ

កៈ ចុះផ្ទះនៅស្រុកនឹងនរណាគេជាអ្នកធ្វើដែរអ៊ុំ?

ខ៖ សាងសងគ្រួសារខ្ញុំនឹងប្តីប្រពន្ធខ្ញុំនឹង

ក៖ អូបាទអ៊ុំ

ខ៖ តែបានចេញមកចឹងពុកក្មេកនៅជិតផ្ទះនឹងជួយមើលថៃអោយ

ក៖ អ៊ុំចេះធ្វើផ្ទះហោស?

ខ៖ ទេគេធ្វើអោយលក្ខណះថាជួលគេនឹងតែប្តីប្រពន្ធរបស់ខ្ញុំជាអ្នកផ្តើមអោយ

ក៖ អូអ៊ុំជាអ្នកអោយលុយណា?

ខ៖ រាល់ការខ្វះខាតគេទៅដោះអោយគេទៅ

ក៖
ចុះអ៊ុំផ្ទះរបស់អ៊ុំពេលដែរធ្វើនឹងដែរអ៊ុំជួលគេអ៊ុំគិតថាគេបានប្រើឧបករណ៍អីគេខ្លះសំរាប់ធ្វើដែរអ៊ុំ?

ខ៖ សុទ្ធតែឈើទាំងអស់

ក៖ អូសុទ្ធឈើទាំងអស់

ខ៖ មានឈើនឹងត្នោត

ក៖ ចុះប៉ុន្តែគិតថាមានអីគេដែរដូចជាដែកឈូស ដែកដាប រឺមួយក៏រណា?

ខ៖ បាទអានឹងវាមានទាំងអស់ជាងគេមានទាំងអស់នឹងមានទាំងអស់

ក៖ ប៉ុន្តែអ៊ុំគិតថាមានអីគេដែរអ៊ុំ?

ខ៖ មានដូចជាដែកគោមួយ

ក៖ ដែកគាស់ ពូថៅ

ខ៖ នឹងហើយដែកគាស់ ពូថៅ មានទាំងញញួរ រណា ហើយមានអាប្រដាប់យើងឈូស

ក៖ ដែកឈូសហើយនឹងដែកដាប?

ខ៖ ដែកឈូសនឹងមានទាំងអស់

កៈ
ចុះអ៊ុំមានជំនាញអីដែរអ៊ុំគិតថាឪពុកម្ដាយរបស់អ៊ុំបានបង្រៀនជំនាញអីដូចជាលក្ខណៈថាជំនាញវេញវល្លិ៍ កូរស្ករ រឺក៏រកម្ហូប រឺមួយក៏ជំនាញអី?

ខៈ ខ្ញុំជំនាញជាងគេគឺខាងរកម្ហូប

កៈ អូជំនាញអ៊ុំរកម្ហូបហោសអ៊ុំ?

ខៈ បាទក្មួយគឺរកម្ហូប

កៈ អូឡើងភ្នំរកម្ហូបហោសអ៊ុំ?

ខៈ នេះសួរតែក្មួយក្មួយៗចៅទៅ

កៈ អូចឹងហោសអ៊ុំ?

ខៈ គាត់រកម្ហូបទាំងយប់ទាំងថ្ងៃបើយប់គាត់អង្គុយចាំមើលត្រី

កៈ ចុះអ៊ុំអាចប្រាប់ពីពេលដែរអ៊ុំលំបាកបានទេដូចជាអ៊ុំលំបាកពេលណាដែរអ៊ុំ?

ខៈ
ពេលដែរពិបាករបស់ខ្ញុំគឺពិបាក2ឆ្នាំពេលដែរខ្ញុំឈឺទៅមាននរណាគេរកស៊ីទៅបើមេគ្រប់គ្រងជួរទៅហើយនឹងអានឹងខ្ញុំពិបាកជាងគេ

កៈ ចុះអ៊ុំឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរអ៊ុំ?

ខៈ
បើតាមនិយាយទៅមូលហេតុនេះខ្ញុំអត់ដឹងដែរធ្វើការជាមួយប្រពន្ធសុខៗចាប់ផ្ដើមចុកយកតែម្ដង

កៈ
ចុះអ៊ុំមានបទពិសោធន៍ល្អៗអីគេខ្លះដែរអ៊ុំគិតថាលក្ខណៈថាការសប្បាយរបស់អ៊ុំនៅពេលណា
លក្ខណៈថារៀបអាពាហ៍ពិពាហ៍អោយកូនចៅរឺមួយក៏អាពាហ៍ពិពាហ៍ខ្លួនឯងដែរអ៊ុំគិតថាសប្បាយជាងគេហាសអ៊ុំ?

ខៈ បើលោកគ្រូនិយាយចឹងខ្ញុំត្រេកអរណាស់ដែរខ្ញុំបានកូន2រូប

កៈ អូបាទអ៊ុំ

ខៈ
ហើយខ្ញុំនៅមានសំណាងដែរបានកូន3នាក់ទៀតនេះតែបើឥឡូវខ្ញុំធ្លាក់ខ្លួនឈឺចឹងខ្ញុំពីមុនសាច់ឈាមខ្ញុំល្អហាសណាខ្ញុំបើបានសំណាងថាបានរៀបចំអោយ3នាក់នឹងទៀតរៀបអោយស្រី3នាក់នឹងទៀតអោយខ្ញុំផុតក៏ផុតទៅក៏អស់ចិត្តដែរតែឥឡូវបានចៅមួយហើយ

កៈ
ចុះកាលពីនៅក្មេងអ៊ុំមានធ្លាប់គិតថាអនាគត់ទៅអ៊ុំមានធ្លាប់ស្រម៉ៃថាអ៊ុំចង់ធ្វើអីអត់លក្ខណៈថាគ្រូពេទ្យ គ្រូបង្រៀន រឺមួយក៏លក្ខណៈថាអ្នកជំនាញអីគេមួយចឹងហាស?

ខៈ ចិត្តខ្ញុំលោកគ្រូខ្ញុំសង្ឃឹមតែប៉ុននេះទេខ្ញុំចង់បានតែចេះអក្សរហើយនឹងចង់បានសុភមង្គលនៅក្នុងក្រុមគ្រួសារខ្ញុំសប្បាយចិត្តណាស់ហើយខ្ញុំមិនចង់បានអីទេ

កៈ
ចុះបើគេចង់អោយអ៊ុំផ្ដែផ្ដាំវិញទៅកូនចៅជំនាន់ក្រោយៗរបស់អ៊ុំហាសតើអ៊ុំចង់ផ្ដែផ្ដាំអីទៅពួកគាត់ទៅកូនចៅរបស់អ៊ុំនឹងកូនក្មួយរបស់អ៊ុំថាអនាគត់ទៅអោយគាត់ខំប្រឹងរៀនដើម្បីអោយគាត់មានអនាគត់ល្អមិនចង់អោយគាត់ដើរលេងផ្ដេសផ្ដាស់មិនចង់អោយគាត់ដើរផ្លូវខុសអីចឹងហាស?

ខៈ
ខ្ញុំដល់ពេលឥឡូវខ្ញុំធ្លាក់ខ្លួនឈឺហើយខ្ញុំលែងចង់ផ្ដែផ្ដាំអីទាំងអស់ពិបាកកូនៗយើងនឹងវាធំៗអស់ហើយតែបើនិយាយទៅខ្ញុំចង់ផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយមិនចង់អោយកូនដើរលេងយប់ព្រលប់ពីព្រោះពេលបច្ចុប្បន្ននឹងមានចេញជាតិថ្នាំច្រើនណាស់អានឹងកូនៗ មិនថាកូនមិនថាក្មួយមិនថាអីទេគឺផ្ដាំទៅទាំងអស់នឹង

កៈ ចឹងមានតែប៉ុណ្ណឹងទេណាអ៊ុំណា?

ខៈ បាទមានតែប៉ុណ្ណឹង

កៈ
បាទចឹងជាចុងក្រោយខ្ញុំអរគុណច្រើនដែរអ៊ុំបានអោយខ្ញុំសំភាសន៍អ៊ុំដែរបានទាក់ទងនឹង

ប្រវត្តិរបស់អ៊ុំហើយខ្ញុំនឹងដាក់ការសំភាសន៍របស់អ៊ុំទៅក្នុងវេបសាយរបស់សាលាហាសអ៊ុំ
បាទអរគុណច្រើនអ៊ុំ៕៕៕